# វិញ្ញាសាប្រឡងគ្រូបង្រៀនអនុវិទ្យាល័យ

# ប្រវត្តិវិទ្យា

## សម័យប្រឡង៖ ១៨ ឧសភា ២០២៤

# វិញ្ញាសាប្រឡងគ្រូបង្រៀនអនុវិទ្យាល័យ

## សម័យប្រឡង ១៨ ឧសភា ២០២៤

## មណ្ឌលប្រឡង៖ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

## ដំណាក់កាលទី២ ឯកទេសប្រវត្តិវិទ្យា-ភូមិវិទ្យា

## ឯកទេសទី១៖ ប្រវត្តិវិទ្យា ម៉ោង១២ដល់២រសៀល

## សំណួរ

១.តើព្រះបាទអង្គដួងមានស្នាព្រះហស្តអ្វីខ្លះ?

២.តើនយោបាយអព្យាក្រឹតផ្តល់គុណសម្បត្តិនិងគុណវិបត្តិអ្វីខ្លះដល់កម្ពុជា?

៣.តើសង្គ្រាមស៊ីវិលជាអ្វី? តើសង្គ្រាមស៊ីវិលនៅអាមេរិកកើតឡើងដោយសារអ្វី? ចូរពន្យល់។

៤.តើរបបខ្មែរក្រហមដួលរលំដោយសារកត្តាអ្វីខ្លះ?

៥.ចូរពណ៌នាពីសមិទ្ធផលរាជរដ្ឋាភិបាលកម្ពុជាតាំងពីឆ្នាំ១៩៩៣ ដល់បច្ចុប្បន្ន។

## អត្រាកំណែក្រៅផ្លូវការ

១. ស្នាព្រះហស្តរបស់ព្រះបាទអង្គដួងមានដូចជា៖

- នយោបាយ៖
    - ព្រះអង្គជាក្សត្រខ្លាំងពូកែជាងក្សត្រមុនៗ
    - ផ្តួចផ្តើមគំនិតធ្វើទំនាក់ទំនងជាមួយបារាំងដើម្បីកាត់បន្ថយឥទ្ធិពលសៀម និងយួននៅលើទឹកដីខ្មែរ
    - ក្នុងរជ្ជកាលព្រះអង្គ ស្រុកខ្មែរមានសុខសន្តិភាពមួយរយៈពេល
    - បង្ក្រាបការបះបោររបស់ពួកចាម្បនៅត្បូងឃ្មុំ
    - ព្យាយាមរក្សាសន្តិភាពជាមួយប្រទេសទាំងពីរ ដោយសុខចិត្តលើកសួយសាអាករមួយឆ្នាំម្តងទៅសៀម បីឆ្នាំម្តងទៅយួន។ បើសិនជាព្រះអង្គធ្វើឱ្យភាគីណាមួយអាក់អន់ស្រពន់ចិត្ត បណ្តាលឱ្យមានសង្គ្រាមទៀតនោះ ភាគីទាំងពីរនឹងពុះចែកប្រទេសកម្ពុជាជាពីរមិនខាន។ដូច្នេះទើបព្រះអង្គរក្សាសន្តិភាព មិនចង់ឱ្យមានសង្គ្រាមទេ។
- រដ្ឋបាល៖
    - កាត់បន្ថយចំនួនខេត្តពី៥២ មក៤០ដើម្បីកាត់បន្ថយការចំណាយ
    - កាត់បន្ថយក្បួនដង្ហែរបស់មន្ត្រីធំៗដើម្បីកាត់បន្ថយថវិកាជាតិ
- សេដ្ឋកិច្ច៖
    - យល់ដឹងពីភាពចាំបាច់នៃសេដ្ឋកិច្ចជាតិ ដោយបានផ្តើមគំនិតធ្វើពាណិជ្ជកម្មអន្តរជាតិឡើងវិញបន្ទាប់ពីអាក់ខានអស់រាប់សតវត្ស

- សាងសង់កំពង់ផែកំពត ដើម្បីជំនួសកំពង់ផែចាស់ដែលអណ្ណាមបានយក
- សាង់សង់ផ្លូវពីកំពង់ផែកំពត មកក្រុងឧដុង្គដើម្បីជំរុញសកម្មភាពពាណិជ្ជកម្ម
- សាងសង់ផ្លូវពីកំពត មកកំពង់ហ្លួង
- ព្រះអង្គបានបោះពុម្ពប្រាក់ដើម្បីប្រើជាមធ្យោបាយដោះដូរក្នុងវិស័យពាណិជ្ជកម្ម ទាក់ទាញឈ្មួញចិន និងឥណ្ឌា
- ក្នុងវិស័យកសិកម្មព្រះអង្គបានហាមមិនឱ្យធ្វើផ្សស់បិទជិតស្ទឹងដើម្បីទុកត្រីនេសាទ និងអាចធ្វើចរាចរណ៍បាន ហាមប្រាមមិនឱ្យបរបាញ់សត្វជាដើម

• កំណែទម្រង់សង្គម៖
  - រៀបចំសណ្តាប់ធ្នាប់សង្គម ដោយដាក់ទណ្ឌកម្មចំពោះជនប្រមឹក អ្នកជក់អាភៀន អ្នកលេងល្បែងស៊ីសង
  - ព្យាយាមលុបបំបាត់របបទាសភាព ព្រះអង្គបានលោះខ្ញុំដាច់ថ្លៃដោយប្រើប្រាស់ព្រះរាជទ្រព្យផ្ទាល់របស់ព្រះអង្គ
  - បង្កើតពន្ធដារថ្មី
  - ហាមតម្លើងការប្រាក់ និងបង្ក្រាបការចងការប្រាក់ខ្ពស់ហួសប្រមាណ
  - ហាមមិនឱ្យកេណ្ឌប្រជាជនបំពេញការងារសាធារណៈនៅរដូវធ្វើស្រែចម្ការ
  - សាងសង់សាលាឆទានដើម្បីចែកទានដល់អ្នកក្រ ទុគ៌តជន

• វប្បធម៌៖
  - ព្រះអង្គជាពុទ្ធសាសនិក ដោយបាននាំយកគម្ពីរព្រះត្រៃបិដកជាច្រើនមកពីស្រុកសៀម
  - ផ្តល់ព្រះរាជទ្រព្យសម្រាប់សាងសង់វត្តអារាម
  - លើកទឹកចិត្តកវីបណ្ឌិតដោយផ្តល់ប្រាក់កាស មធ្យោបាយផ្សេងៗចំពោះជនណាដែលចង់ស្វែករកចំណេះវិជ្ជា
  - ព្រះអង្គជាព្រះរាជកវីមានដូចជារឿងចំប៉ាថោង រឿងកាកី ច្បាប់ស្រីជាដើម

• ពង្រឹងច្បាប់៖
  - ដកមន្ត្រីគ្មានសមត្ថភាពចេញពីរាជការ ដាក់ទោសពួកមន្ត្រីដែលមិនគោរពព្រះរាជបញ្ជារបស់ទ្រង់ ហាមប្រាមមន្ត្រីមិនឱ្យផឹកស្រា ជក់អាភៀន

២. នយោបាយអព្យាក្រឹត្យបានផ្តល់គុណសម្បត្តិ និងគុណវិបត្តិដូចជា៖

• គុណសម្បត្តិ
  - កម្ពុជាមានការអភិវឌ្ឍលើគ្រប់វិស័យ
  - កម្ពុជាមានសុខសន្តិភាពរយៈពេល១៥ឆ្នាំ

- ក្រុមប្រឆាំងមិនហ៊ានប៉ះពាល់ និងទទួលស្គាល់គុណសម្បត្តិនយោបាយអព្យាក្រឹត្យ
- កម្ពុជាទទួលបានជំនួយពីមហាអំណាចទាំងពីរដើម្បីអភិវឌ្ឍជាតិ
- ធ្វើឱ្យឯកភាពជាតិ ស្ថិតក្រោមរាជបល្ល័ង្កតែមួយបានមួយរយៈពេល
- រក្សាបូរណភាពទឹកដី ឯករាជ្យកម្ពុជា
- កម្ពុជាមានសិទ្ធិសេរីភាពក្នុងការធ្វើទំនាក់ទំនងជាមួយប្រទេសដទៃទៀត

- គុណវិបត្តិ
  - ការបែកបាក់ជាតិរវាងមន្ត្រីនៅពេលនយោបាយអព្យាក្រឹតមិនចំគោលដៅ
  - មន្ត្រីមួយចំនួនចាំតែឱកាសដើម្បីវាយប្រហារសង្គមរាស្ត្រនិយម
  - ធ្វើឱ្យរដ្ឋាភិបាលសង្គមរាស្ត្រនិយមផ្លាស់ប្តូរជាញឹកញាប់ ម្តងងាកទៅឆ្វេង ម្តងងាកទៅស្តាំ
  - ថៃគាំទ្រចលនាខ្មែរសេរីដែលជាចលនាប្រឆាំងនឹងរបបសង្គមរាស្ត្រ។

៣. សង្គ្រាមស៊ីវិលគឺជាការប្រយុទ្ធគ្នា ការច្បាំងគ្នារវាងជាតិសាសន៍ដូចគ្នា។ សង្គ្រាមស៊ីវិលនៅអាម៉េរិកកើតឡើងដោយសារមូលហេតុដូចជា៖

- ការប្រកាន់ពូជសាសន៍ដោយប្រើទាសករស្បែកខ្មៅដូចសត្វធាតុ
- រដ្ឋខាងជើងដែលជារដ្ឋជឿនលឿន ចង់ឱ្យលុបបំបាត់របបទាសភាពនៅរដ្ឋខាងត្បូង
- ការគាបសង្កត់ពីសំណាក់រដ្ឋខាងជើង ធ្វើឱ្យរដ្ឋខាងត្បូងចង់បំបែករដ្ឋចេញ។

៤. របបខ្មែរក្រហមដួលរលំដោយសារកត្តាដូចជា៖

- កត្តាប្រជាជនស្អប់ប៉ុល ពតព្រោះរបបនេះបាន៖
  - បង្ខំឱ្យប្រជាជនធ្វើការជាទម្ងន់ហួសបាក់កម្លាំង
  - កាប់សម្លាប់ប្រជាជនឥតត្រាប្រណី
  - ប្រើមនុស្សឱ្យធ្វើការដូចសត្វធាតុ
  - គ្មានអាហារបរិភោគ គ្មានថ្នាំសង្កូវ រង់ចាំតែសេចក្តីស្លាប់
  - រស់នៅដូចគុកឥតជញ្ជាំង
- ការសម្រិតសម្រាំងយកមនុស្សបដិវត្តបរិសុទ្ធ
  - បក្សកុម្មុយនិស្តកម្ពុជាបានសម្រិតសម្រាំងយកតែមនុស្សបដិវត្តបរិសុទ្ធធ្វើឱ្យមានការបែកបាក់ផ្ទៃក្នុង លែងទុកចិត្តគ្នា
  - ការបែកបាក់គ្នារវាងសមាជិកបក្ស
- ការធ្វើសង្គ្រាមជាមួយវៀតណាម
  - ចាប់ពីឆ្នាំ១៩៧៥ ខ្មែរក្រហមបានធ្វើសង្គ្រាមជាមួយវៀតណាម
  - វៀតណាមជាប្រទេសដែលធ្លាប់បទពិសោធន៍សង្គ្រាមច្រើន

- វៀតណាមជាប្រទេសដែលមានជំនួយពីមហាអំណាចសូវៀត
- ការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា
    - នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាត្រូវបានបង្កើតឡើងដើម្បីផ្តួលរំលំរបបខ្មែរក្រហម
    - នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៨ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាមបានវាយរំលំរបបខ្មែរក្រហម
- កត្តាសេដ្ឋកិច្ច
    - ការអនុវត្តគោលនយោបាយសេដ្ឋកិច្ចខ្លួនពឹងខ្លួន ឯករាជ្យម្ចាស់ការធ្វើឱ្យសេដ្ឋកិច្ចខ្មែរក្រហមធ្លាក់ចុះខ្សោយ
    - សេដ្ឋកិច្ចខ្មែរក្រហមមិនអាចផ្គត់ផ្គង់ប្រជាជនខ្លួនឯងបាន
    - សេដ្ឋកិច្ចខ្មែរក្រហមពឹងផ្អែកលើវិស័យកសិកម្មតែមួយមុខ ចំណែកវិស័យផ្សេងៗទៀតមិនមានសកម្មភាព
- កត្តាសង្គម
    - ប្រជាជន កងទ័ពអស់ជំនឿលើរបបខ្មែរក្រហម
    - ប្រជាជនបាក់កម្លាំង អស់សង្ឃឹមគ្រប់គ្នា គ្មានកម្លាំងតស៊ូជាមួយទ័ពវៀតណាម។

៥. ពណ៌នាពីសមិទ្ធផលរបស់រាជរដ្ឋាភិបាលកម្ពុជាចាប់តាំងពីឆ្នាំ១៩៩៣ ដល់បច្ចុប្បន្ន៖

- នយោបាយក្នុងប្រទេស
    - អនុវត្តនយោបាយឈ្នះឈ្នះ ( ដោយរំលាយអង្គការចាត់តាំងខ្មែរក្រហម និងធ្វើសមាហរណកម្មកងកម្លាំងខ្មែរក្រហមឲ្យមកចូលរួមរស់នៅជាមួយរាជរដ្ឋាភិបាលនៅឆ្នាំ ១៩៩៨ នាំមកនូវសន្តិភាពូបនីយកម្មនៅកម្ពុជា )
    - រៀបចំការបោះឆ្នោតដោយខ្លួនឯងប្រកបដោយជោគជ័យទៅតាមលទ្ធិប្រជាធិបតេយ្យ
    - កំណែទម្រង់គ្រប់វិស័យ ( អប់រំ រដ្ឋបាល តុលាការ និងកងកម្លាំងប្រដាប់អាវុធ )
    - កម្ពុជាប្រកាន់យកលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស
    - រាជរដ្ឋាភិបាលបានអនុវត្តនយោបាយ យុទ្ធសាស្ត្រ ( ត្រីកោណ និងយុទ្ធសាស្ត្រចតុកោណ )
    - និងមតិផ្សេងៗទៀត
- នយោបាយក្រៅប្រទេស
    - កម្ពុជាក្លាយជាសមាជិកអាស៊ាន ( ស្មើមុខស្មើមាត់ជាមួយប្រទេសនានា )
    - កម្ពុជាចូលជាសមាជិក WTO និងអង្គការនានា...
    - ចូលរួមថែរក្សាសន្តិភាពពិភពលោក ( កងទ័ពមួកខៀវ )

- ធ្វើជាម្ចាស់ផ្ទះក្នុងកិច្ចប្រជុំសមាគមន៍អាស៊ាន
  - និងមតិផ្សេងៗទៀត
- ផ្នែកសេដ្ឋកិច្ច
  - កសិកម្មមានការរីកចម្រើនដោយរដ្ឋាភិបាលយកចិត្តទុកដាក់ក្នុងការបង្កើតប្រព័ន្ធធារាស្រ្ត ការបង្កាត់ពូជ
  - អនុវត្តសេដ្ឋកិច្ចទីផ្សារសេរី កម្ពុជាបានក្លាយជាកន្លែងវិនិយោគទុនដ៏ទាក់ទាញ
  - វិស័យឧស្សាហកម្មមានការរីកចម្រើនផ្នែករោងចក្រ សហគ្រាស
  - ការធ្វើពាណិជ្ជកម្មក៏មានភាពងាយស្រួលជាងមុន
  - ប្រជាពលរដ្ឋអាចរកការងារធ្វើបានយ៉ាងទូលំទូលាយ ទាំងក្នុងប្រទេសនិងតំបន់
  - សេដ្ឋកិច្ចមានកំណើនខ្ពស់ក្នុងរយៈពេលវែង និងចំណូលថវិកាក៏ឡើងជាប្រចាំ
  - មានកំណើនទេសចរណ៍ដែលនាំឲ្យមានកំណើនការងារ និងប្រាក់ចំណូលដល់ប្រជាជនទេសចរណ៍ធម្មជាតិ ( ឆ្នេរសមុទ្រស្អាត ទឹកជ្រោះ .... ) ទេសចរណ៍វប្បធម៌ ( ប្រាសាទអង្គរវត្ត ប្រាសាទព្រះវិហារ ... )
  - ការចូលជាសមាជិកអាស៊ានក៏ជាផ្នែកមួយដែលជំរុញឲ្យសេដ្ឋកិច្ចកម្ពុជាមាន កំណើនជា រៀងរាល់ឆ្នាំផងដែរ
  - មានការកសាងហេដ្ឋារចនាសម្ព័ន្ធ ស្ពាន ស្ពានអាកាស ផ្លូវដែក និងផ្លូវថ្នល់ និងពង្រីកអាកាសយានដ្ឋាន ព្រមទាំងការលើកលែងទិដ្ឋាការ

- ផ្នែកអប់រំ វប្បធម៌
  - កសាងសាលារៀន ពីទីក្រុងដល់ជនបទដាច់ស្រយោល ( ចំណេះដឹង អាហាររូបករណ៍សម្រាប់និស្សិតបានធ្វើឲ្យមន្ត្រីរាជការប្រជាជននិងយុវជនកម្ពុជាបានរៀនសូត្រ និងទទួលបាននូវឱកាសល្អៗជាច្រើន )
  - បង្កើតនិងជួសជុលកីឡាដ្ឋាន បណ្តុះបណ្តាលជំនាញ កីឡាករទទួលបានមេដាយ
  - មាស ប្រាក់ សំរិទ្ធ លើឆាកអន្តរជាតិ
  - អភិរក្សសម្បត្តិវប្បធម៌ទាំងរូបីយ និងអរូបីយ ព្រមទាំងបានដាក់បញ្ចូលសម្បត្តិវប្បធម៌កម្ពុជាបេតិកភណ្ឌពិភពលោក ( រមណីយដ្ឋានអង្គរ ប្រាសាទព្រះវិហារ ប្រាសាទសំបូរព្រៃគុក របាំព្រះរាជទ្រព្យ ល្ខោនស្រមោលស្បែកធំ ចាប៉ីដងវែង ... )
- ផ្នែកសង្គមកិច្ច

- កម្ពុជាទទួលបាននូវកិច្ចសហការជាមួយប្រទេសក្នុងតំបន់ក្នុងការថែរក្សាសន្តិភាពនិងសន្តិសុខសង្គម ទប់ស្កាត់ការជួញដូរមនុស្ស ថ្នាំញៀន និងអំពើភេរវកម្ម
- មានការកសាងកោមណ្ឌលសុខភាព មន្ទីរពេទ្យ នៅតាមឃុំ សង្កាត់ ស្រុក ខណ្ឌ
- មានសេរីភាពសារព័ត៌មាន និងអនុញ្ញាតឲ្យមានសិទ្ធិសេរីភាពក្នុងការបង្កើតអង្គការសង្គមស៊ីវិល
- សមភាពយេនឌ័រ ( ផ្ដល់សិទ្ធិដល់ស្ត្រីក្នុងការធ្វើសេចក្ដីសម្រេចចិត្ត )
- មានការជួយគ្នាទៅវិញទៅមករវាងប្រទេសសមាជិក តាមរយៈការផ្ទេរបទពិសោធន៍។

**រៀបរៀងដោយជួប គារម្យ/ គរុសិស្សឯកទេសប្រវត្តិវិទ្យា+ភូមិវិទ្យាជំនាន់ទី៣២**

**២៨ សីហា ២០២៤**